អង្គការនារីដើម្បីសន្តិភាព
Women Peace Makers

# ឱកាសការងារ

| | |
|---|---|
| **តួនាទី** | អ្នកសម្របសម្រួលសហគមន៍ ចំនួន ២រូប |
| **ទីតាំង** | ស្រុកជុំគិរី ខេត្តកំពត |
| **ប្រាក់ខែ** | ចន្លោះ ២០០ដុល្លា-២៥០ដុល្លា(គត់) និងអត្ថប្រយោជន៍ផ្សេងទៀត |
| **រាយការណ៍** | អ្នកសម្របសម្រួលគម្រោង |
| **ការកំណត់ឈប់ទទួលពាក្យ** | ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ |

## អំពីអង្គការនារីដើម្បីសន្តិភាព

អង្គការនារីដើម្បីសន្តិភាព (WPM) ជាអង្គការក្នុងស្រុកមួយ ធ្វើការមិនស្វែងរកប្រាក់ចំណេញ និងមិនមាននិន្នាការនយោបាយណាមួយឡើយ។ អង្គការនារីដើម្បីសន្តិភាព មានទស្សនៈវិស័យ គឺចង់ឃើញសង្គមមួយពោរពេញដោយសន្តិភាព និងយុត្តិធម៌យេនឌ័រ ដែលអាចអោយមនុស្សគ្រប់រូប សម្រេចបាននូវសក្តានុពលភាព ពេញលេញជាមនុស្ស និងជៀសផុតពីហឹង្សាគ្រប់ប្រភេទរួមទាំងហឹង្សាលើយេនឌ័ដោយមិនប្រកាន់អត្តសញ្ញាណ ឬសមត្ថភាពរបស់បុគ្គលនោះឡើយ។ អង្គការនារីដើម្បីសន្តិភាពមានបេសកម្មគាំទ្រការពង្រឹងភាពអង់អាចរបស់ស្ត្រី និងយុវជន ទប់ស្កាត់អំពើហិង្សា រួមទាំងអំពើហឹង្សាផ្អែកលើយេនឌ័រ កសាងសន្តិភាព និងដោះស្រាយទំនាស់ដោយផ្តល់ជាឧបករណ៍(វិធីសាស្ត្រ) និងការកសាងបរិយាកាសអំណោយផលនិងការច្នៃប្រឌិតសម្រាប់ការសន្ទនានិងការយល់ដឹងអោយបានស៊ីជម្រៅទៅលើបញ្ហាយេនឌ័រនិងការកសាងសន្តិភាព។

## គោលបំណង

អង្គការនារីដើម្បីសន្តិភាព កំពុងតែអនុវត្តគម្រោងមួយដែលមានឈ្មោះថា"**រួមគ្នាដើម្បីគាំទ្រសិទ្ធិស្ត្រី**" ក្រោមគាំទ្រពី **ទីភ្នាក់ងារជំនួយអាមេរិក USAID**។ គម្រោងនេះមានគោលបំណងផ្សាភ្ជាប់សហគមន៍និងសង្គមស៊ីវិលជាមួយរដ្ឋាភិបាលតាមរយៈការបង្កើនការចូលរួម និងភាពជាអ្នកដឹកនាំរបស់ ស្ត្រី និងយុវជនក្នុងដំណើរការសម្រេចចិត្តក្នុងប្រទេសកម្ពុជា។ ថ្មីៗនេះ អង្គការនារីដើម្បីសន្តិភាព កំពុងស្វែងរកអ្នកសម្របសម្រួលសហគមន៍ចំនួន២នាក់ ដើម្បីអនុវត្តន៍គម្រោង "**រួមគ្នាដើម្បីគាំទ្រសិទ្ធិស្ត្រី**"។

## តួនាទី និងការទទួលខុសត្រូវ

អ្នកសម្របសម្រួលសហគមន៍នឹងធ្វើការងារសហការណ៍ផ្ទាល់ជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងដៃគូរពាក់ពន្ធ័តាមរយៈ ការផ្តល់បច្ចេកទេស និងការគាំទ្រសមត្ថភាពរបស់ពួកគេ ដោយធានាថា ស្ត្រី យុវជន និងក្រុមភាគតិចផ្សេងទៀតមានឱកាសស្មើគ្នាក្នុងការចូលរួមសកម្មភាពគម្រោងនេះ។ ពួកគេនឹងត្រូវគាំទ្រដោយផ្ទាល់ដោយអ្នកសម្របសម្រួលគម្រោង (Project

coordinator)។ ពួកគេនឹងធ្វើការងារផ្ទាល់នៅក្នុងឃុំទាំង៦នៃស្រុកជុំគិរី ជាមួយក្រុមគោលដៅ តាមរយៈការគាំទ្រនិងការលើកទឹកចិត្តក្រុមគោលដៅ និងអ្នកពាក់ពន្ធ័ក្នុងការចូលរួមក្នុងគម្រោង។ តួនាទីរបស់អ្នកសម្របសម្រួល៖

**កសាងទំនាក់ទំនងនិងកិច្ចសហការណ៍**

- កសាងទំនាក់ទំនងល្អនិងកិច្ចសហការណ៍ល្អជាមួយអ្នកពាក់ពន្ធ័ក្នុងមូលដ្ឋានរួមមានមន្ទី ការិយាល័យ អាជ្ញាធរមូលដ្ឋាន និងជនបង្គោលយេនឌ័រក្នុងសហគមន៍
- គាំទ្រនិងលើកទឹកចិត្តក្រុមផ្សេងៗនៅសហគមន៍រួមមាន ក្រុមស្ត្រី ក្រុមយុវជន និងក្រុមភាគតិចដើម្បីពួកគេបានចូលរួមសកម្មនៅក្នុងសកម្មភាពនៃគម្រោង។
- សម្របសម្រួលសកម្មភាពកិច្ចពិភាក្សាជាមួយថ្នាក់ស្រុក ឃុំ ភូមិ និងអ្នកពាក់ពន្ធផ្សេងទៀត
- ចែករំលែកពត៌មាននិងគាំទ្រដល់សកម្មភាពរបស់គម្រោងនានារបស់អង្គការនារីដើម្បីសន្តិក្នុងការអនុត្តន៍សកម្មភាពគម្រោងឬកម្មវិធី។
- គាំទ្រក្រុមជនបង្គោល ក្រុមអភិវឌ្ឍន៍សមត្ថភាព និងបណ្តាញផ្សេងៗទៀតដើម្បីជម្រុញនូវប្រសិទ្ធភាពនៃការអនុវត្តន៍ការងាររបស់ពួកគេ។

**ការអនុវត្តសកម្មភាព**

- រៀបចំផែនការប្រចាំសប្តាហ៍ និងផែនការសកម្មភាពរយៈពេលបីខែ
- ធានារាល់សកម្មភាពទាំងអស់ត្រូវបានបំពេញទៅតាមពេលវេលាកំណត់
- សម្របសម្រួល និងកសាងសមត្ថភាពក្នុងការបញ្ជ្រៀបយេនឌ័រដល់ក្រុមយុវជន ក្រុមស្ត្រី តាមរយៈ វគ្គបណ្តុះបណ្តាល តាមដាន និងផ្តល់ជាបច្ចេកទេស
- ផ្តល់បច្ចេកទេសគាំទ្រ និងចែករំលែកចំណេះដឹងជាមួយក្រុមជនបង្គោលយេនឌ័រ ក្រុមយុវជន ក្រុមស្ត្រី ដើម្បីរៀបចំសកម្មភាពដូចជា រៀបចំវេទិកាសាធារណៈ យុទ្ធនាការក្នុងបញ្ចប់អំពើ ហឹង្សាប្រឆាំងស្ត្រីនិងកុមារ។

**របាយការណ៍និងការតាមដានត្រួតពិនិត្យ**

- តាមដានរាល់សកម្មភាពគម្រោង រៀបចំផែនការប្រចាំសប្តាហ៍ និងផែនការសកម្មភាពប្រចាំត្រីមាស (បីខែ)ទៅតាមផែនការប្រចាំឆ្នាំនៃគម្រោង។
- រៀបចំផែនការថវិកាសម្រាប់សកម្មភាព ត្រួតពិនិត្យ និងតាមដានការចំណាយថវិកា
- សរសេររបាយណ៍តាមសកម្មភាព របាយការណ៍ ៦ខែនិងមួយឆ្នាំនិងរាយការណ៍ទៅអ្នកសម្របសម្រួលគម្រោង
- រៀបចំទុកដាក់ទិន្នពត៌មាន ឯកសារ និងករណីសិក្សានៃការផ្លាស់ប្តូរក្រុមគោលដៅនៃគម្រោង

## បទពិសោធន៍ និងសមត្ថភាព

- ធ្លាប់មានបទពិសោធន៍ធ្វើការជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋាន ដូចជាសម្របសម្រួល រៀបចំការប្រជុំ/កិច្ចពិភាក្សា និងបទពិសោធន៍ក្នុងការរៀបចំវេទិកាសាធារណៈនិងសកម្មភាពសិក្សាផ្សេងៗ
- មានចំនេះដឹងទាក់ទងនឹងយេនឌ័រ សិទ្ធិមនុស្ស និងការងារអភិវឌ្ឍន៍សហគមន៍
- មានឥរិយាបថវិជ្ជមាន មានទំនួលខុសត្រូវខ្ពស់ និងមានការតាំងចិត្ត

- មានឆន្ទៈក្នុងការធ្វើការងារដើម្បីបញ្ចប់រាល់ទំរង់នៃអំពើហិង្សាប្រឆាំងស្ត្រីភេទ និងកុមារ លើកកម្ពស់សមភាពយេនឌ័រ និងគាំទ្រភាពជាអ្នកដឹកនាំរបស់ស្ត្រី
- ជាបុគ្គលគំរូល្អសម្រាប់កុមារនិងមនុស្សនៅក្នុងសហគមន៍

## គុណសម្បត្តិ

- មានសញ្ញាទុតិយភូមិ ឬកម្រិតប្រហាក់ប្រហែល
- មានជំនាញក្នុងទំនាក់ទំនងជាភាសាខ្មែរទាំងសរសេរនិងនិយាយ និងអាចប្រើប្រាស់ភាសាអង់គ្លេសបានខ្លះ
- មានបំនេះដឹង និងប្រើប្រាស់កុំព្យូទ័រ Microsoft office បាន

## របៀបក្នុងការដាក់ពាក្យ៖

បេក្ខជនអាចផ្ញើរ CV និងលិខិតចំណាប់អារម្មណ៍ការងារ (Cover letter) របស់លោកអ្នកមកកាន់អ៊ីម៉ែល៖ sreynich.k@women-peacemakers.org ។ សម្រាប់លោកអ្នកដែលនៅស្រុកជុំគិរី លោកអ្នកអាចផ្ញើរ CV និងCover letter របស់លោកអ្នកតាមរយៈ**លោក អ៊ូ សារិន** ប្រធានអង្គការអភិវឌ្ឍជនពិការ មានទីស្នាក់ការនៅសាលាឃុំស្រែចែង ស្រុកជុំគិរី ខេត្តកំពត ឬទំនាក់ទំនងតាមរយៈលេខ៖ 070978336/092504896។

**ថ្ងៃកំណត់ឈប់ទទួលពាក្យនៅថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០១៩ នាម៉ោង ៥.00 នាទីល្ងាច។**

## ព័ត៌មានបន្ថែមសុំទំនាក់ទំនង៖

- កញ្ញាខាត់ ស្រីនិច ទូរសព្ទ័លេខ៖ 070 369 577
- ពត៌មានបន្ថែមសូមលោកអ្នកចូលទៅកាន់វេបសាយ៖ wpmcambodia.org និងហ្វេសប៊ុក Women Peace Makers ។